# គណបក្ស សិទ្ធិមនុស្ស

## HUMAN RIGHTS PARTY

បំរើ ការពារ កសាង

លេខ...០២១៧...គ.ស.ម
/០៩

ភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩

# សេចក្តីថ្លែងការណ៍

តំណាងរាស្ត្រមកពី **គណបក្សសិទ្ធិមនុស្ស** "គ.ស.ម." ប្រកាន់ជានិច្ចនូវគោលការណ៍ គោរព និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរ ។

តំណាងរាស្ត្រទាំងបីរូបមកពី **គណបក្សសិទ្ធិមនុស្ស** មិនបានលើកដៃគាំទ្រសេចក្តីព្រាងច្បាប់ "**ក្រមព្រហ្មទណ្ឌ** " ទាំងមូលនោះទេ ។

តំណាងរាស្ត្រមកពី **គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា ច្បាប់ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាទើបបានអនុម័តថ្ងៃនេះ អាចជាអាវុធមុខពីរ ។ **ទីមួយល្អគឺ :** អាចទប់ស្កាត់បង្ក្រាប និង ផ្តន្ទាទោសដល់ជនល្មើសដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ និង**ទីពីរមិនល្អគឺ :** អាចប៉ះពាល់ដល់សិទ្ធិសេរីភាពសម្តែងមតិរបស់ប្រជាពលរដ្ឋខ្មែរ ។

តំណាងរាស្ត្រមកពី **គណបក្សសិទ្ធិមនុស្ស** បានគាំទ្រនូវមាត្រាមួយចំនួននៃច្បាប់នេះ ប៉ុន្តែយើងមិនបានគាំទ្រនូវមាត្រាមួយចំនួនដែលប្រជាពលរដ្ឋខ្មែរអ្នកទន់ខ្សោយ និងអង្គការក្រៅរដ្ឋាភិបាលមានការព្រួយបារម្ភ ហើយមិនត្រូវបានរដ្ឋសភា និង តំណាងរាជរដ្ឋាភិបាលធ្វើការកែសម្រួលទាល់តែសោះក្នុងសភាពេញអង្គ ។ ចំណុចដែលមានការព្រួយបារម្ភ និងដែលយើងយល់ថា មិនច្បាស់លាស់ ហើយដែលយើងមិនគាំទ្រនោះមានជាអាទិ៍ដូចជា មាត្រាមួយចំនួនដែលចែងមិនច្បាស់លាស់អំពី **បទបរិហារកេរ្តិ៍ បទប្រមាថ បទញុះញង់**ជាដើម ។ ព្រោះមាត្រាទាំងនោះអាចផ្តល់ឱកាសឱ្យគេបកស្រាយពេលអនុវត្ត ប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកទន់ខ្សោយ ឬ អ្នកនយោបាយជំទាស់ ។

តំណាងរាស្ត្រ **គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា ព្រះរាជាណាចក្រកម្ពុជា ត្រូវការជាចាំបាច់នូវច្បាប់ក្រមព្រហ្មទណ្ឌ ដើម្បីអោយកម្ពុជាអាចអនុវត្តនូវគោលការណ៍នីតិរដ្ឋបាន ក៏ប៉ុន្តែនីតិរដ្ឋមិនមែនគ្រាន់តែមានច្បាប់ ហើយច្បាប់នោះធ្វើឱ្យអាចអនុវត្តរំលោភលើសិទ្ធិសេរីភាពប្រជាពលរដ្ឋនោះទេ ។

**សំរាប់ពត៌មានបន្ថែម :**

សូមទាក់ទង : ០១១ ៧៧៧ ៧៥០ / ០១៦ ៤៣៥ ១០៦

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com | Website: www.hrpcambodia.info